(អត្ថបទបកប្រែក្រៅផ្លូវការ)

# សេចក្តីប្រកាសរួម
# រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

* * * * * * * * *

តបតាមការអញ្ជើញរបស់**ឯកឧត្តម លី ឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ពីថ្ងៃទី១៤ ដល់ ១៦ ខែកញ្ញា ឆ្នាំ២០២៣។ ក្នុងឱកាសទស្សនកិច្ចនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានមានជំនួបជាមួយ**ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីចិន ដោយបានផ្លាស់ប្តូរទស្សនៈគ្នាយ៉ាងស៊ីជម្រៅលើការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី និងពិភាក្សាគ្នាលើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍រួម ជាការកំណត់ទិសដៅសម្រាប់អនាគតនៃទំនាក់ទំនងកម្ពុជា-ចិន។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានជួបពិភាក្សាការងារជាមួយ**ឯកឧត្តមនាយករដ្ឋមន្ត្រី លី ឈាង** នាយករដ្ឋមន្ត្រីចិន និងជួបជាមួយ**ឯកឧត្តម ចាវ ឡឺជី** ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនចិន។

១. ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍយ៉ាងធំធេងនៃទំនាក់ទំនងកម្ពុជា-ចិន ដែលត្រូវបានពូនជ្រំដោយយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំជំនាន់ក្រោយៗ នៃប្រទេសទាំងពីរ និងកំពុងបន្តរីកចំរើនកាន់តែរឹងមាំឥតឈប់ឈរថែមទៀត ក្នុងរយៈពេល ៦៥ ឆ្នាំនេះ ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូត។ ភាគីទាំងពីរសង្កត់ធ្ងន់ថា មិនថាស្ថានភាពអន្តរជាតិប្រែប្រួលយ៉ាងណានោះទេ ភាគីទាំងពីរនឹងអភិវឌ្ឍឥតឈប់ឈរនូវទំនាក់ទំនងមិត្តភាពយូរអង្វែងរបស់ខ្លួន និងធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការ ដើម្បីផលប្រយោជន៍ទៅវិញទៅមក ក្នុងគោលបំណងលើកកម្ពស់ការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដារខ្ពស់ ក្នុងយុគសម័យថ្មី ដើម្បីជាការបង្ហាញអំពីសហគមន៍វាសនារួមសម្រាប់មនុស្សជាតិ។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនៃព្រឹត្តិការណ៍ «ឆ្នាំមិត្តភាពកម្ពុជា-ចិន» ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៥ នៃទំនាក់ទំនងការទូត និងនៅតែមានឆន្ទៈបន្តទំនាក់ទំនងមិត្តភាពជាប្រពៃណីតាមរយៈថ្នាក់ដឹកនាំជំនាន់ក្រោយៗ។

២. ភាគីទាំងពីរបញ្ជាក់ឡើងវិញនូវការគោរព និងគាំទ្រគ្នាទៅវិញទៅមកចំពោះជម្រើសនៃមាគ៌ាអភិវឌ្ឍន៍ដែលស្របនឹងលក្ខខណ្ឌជាតិរៀងៗខ្លួន។ ភាគីកម្ពុជាកោតសរសើរនូវសមិទ្ធផលដ៏ធំធេងរបស់ប្រទេសចិនក្នុងទសវត្សរ៍ នៃយុគសម័យថ្មី និងទំនើបភាវូបនីយកម្មរបស់ចិន ដែលផ្តល់នូវជម្រើសដល់ទំនើបភាវូបនីយកម្មសម្រាប់មនុស្សជាតិ និងកាលានុវត្តភាពថ្មីៗសម្រាប់កម្ពុជា។ វាត្រូវបានគេជឿជាក់ថា ប្រទេសចិននឹងសម្រេចបាននូវគោលដៅសតវត្សទី២របស់ខ្លួន ក្នុងការកសាងប្រទេសសង្គមនិយមទំនើបដ៏អស្ចារ្យមួយលើគ្រប់វិស័យ ដើម្បីក្លាយជាប្រជាជាតិរុងរឿងដ៏អស្ចារ្យមួយតាមរយៈទំនើបភាវូបនីយកម្មរបស់ចិន។ ភាគីចិនវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលសេដ្ឋកិច្ច និងសង្គម

របស់កម្ពុជា ហើយជឿជាក់យ៉ាងមុតមាំថា ក្រោមម្លប់របស់**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលថ្មីកម្ពុជាដែលមាន**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ជាប្រមុខ កម្ពុជានឹងបន្តសម្រេចបាននូវវឌ្ឍនភាពថ្មីៗ ក្នុងការអភិវឌ្ឍជាតិ និងសុខុមាលភាពជូនប្រជាពលរដ្ឋ ព្រមទាំងដើរតួនាទីកាន់តែសំខាន់ក្នុងការថែរក្សាសន្តិភាព និងវិបុលភាព នៅក្នុងតំបន់ និងពិភពលោក។

៣. ភាគីចិនបញ្ជាក់ជាថ្មីនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីការពារអធិបតេយ្យភាពជាតិ សន្តិសុខ និងប្រយោជន៍នៃការអភិវឌ្ឍ ខណៈបញ្ជាក់ពីការប្រឆាំងដាច់ខាត ចំពោះការជ្រៀតជ្រែកពីបរទេសចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។

ភាគីកម្ពុជាបញ្ជាក់ជាថ្មីអំពីការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវ «គោលនយោបាយចិនមួយ» ដែលរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន គឺជារដ្ឋាភិបាលស្របច្បាប់តែមួយគត់ តំណាងឱ្យប្រទេសចិនទាំងមូល ហើយតៃវ៉ាន់គឺជាផ្នែកមួយមិនអាចកាត់ផ្តាច់ចេញពីទឹកដី និងជាកិច្ចការផ្ទៃក្នុងរបស់ចិន ដែលមិនអនុញ្ញាតឱ្យមានការជ្រៀតជ្រែកពីបរទេសឡើយ។ កម្ពុជាប្រឆាំងនឹងការប៉ុនប៉ងនានាក្នុងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ចិន ឬរារាំង ឬទប់ទល់នឹងប្រទេសចិន ក្រោមឧបាយកលយកបញ្ហាតៃវ៉ាន់ជាលេស ឬសកម្មភាពបំបែកខ្លួនតាមទម្រង់ណាមួយដើម្បីទាមទារ «ឯករាជ្យភាពតៃវ៉ាន់»។ កម្ពុជាគាំទ្រយ៉ាងម៉ឺងម៉ាត់នូវកិច្ចប្រឹងប្រែងនានារបស់ចិន ដើម្បីសម្រេចបាននូវការបង្រួបបង្រួមជាតិ និងមិនបង្កើតទំនាក់ទំនងផ្លូវការជាមួយតៃវ៉ាន់ទោះក្នុងទម្រង់ណាមួយក៏ដោយ។

ភាគីទាំងពីរបញ្ជាក់ពីការប្រឆាំងដាច់ខាតចំពោះការធ្វើនយោបាយលើបញ្ហាសិទ្ធមនុស្ស ការអនុវត្តស្តង់ដារពីរ និងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ក្រោមហេតុផលសិទ្ធមនុស្ស ឬប្រជាធិបតេយ្យ។ ភាគីទាំងពីរឯកភាពគ្នាពង្រឹងកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅ និងបដិវត្តន៍ពណ៌។

៤. ភាគីទាំងពីរឯកភាពគ្នារក្សាការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រកម្រិតខ្ពស់ ដើម្បីជំរុញការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការលើទំនាក់ទំនងទ្វេភាគី និងបញ្ហាសំខាន់ៗដែលជាការព្រួយបារម្ភរួម។ ភាគីទាំងពីរឯកភាពគ្នាផ្តល់តួនាទីពេញលេញដល់គណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ក្នុងការអនុវត្តផែនការសកម្មភាពនៃការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន (ឆ្នាំ២០២៤-២០២៨) ព្រមទាំងតួនាទីនានារបស់រដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងសភាតំណាងប្រជាជនចិន គណៈកម្មាធិការជាតិនៃសភាប្រឹក្សានយោបាយប្រជាជនចិន ក៏ដូចជាបណ្តាញទំនាក់ទំនងបក្ស ព្រមទាំងអនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូររវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សកុម្មុយនីស្តចិន ក្នុងគោលបំណងធ្វើឱ្យស៊ីជម្រៅនូវការផ្លាស់ប្តូរបទពិសោធន៍លើអភិបាលកិច្ច កិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងបំពេញបន្ថែមឱ្យកាន់តែប្រសើរឡើងនូវសហគមន៍វាសនារួមកម្ពុជា-ចិនក្នុងយុគសម័យថ្មី។

៥. ភាគីទាំងពីរឯកភាពគ្នាធ្វើឱ្យស៊ីជម្រៅនូវការបន្សីគ្នាជាយុទ្ធសាស្ត្រ រវាងយុទ្ធសាស្ត្របញ្ចកោណ និងគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ និងផ្តោតលើការអភិវឌ្ឍកិច្ចសហប្រតិបត្តិការត្បូងពេជ្រ ដែលមានវិស័យអាទិភាពចំនួន០៦ ដើម្បីធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន និងសម្រេចបាននូវការអភិវឌ្ឍរួមប្រកបដោយចីរភាព និងគុណភាពខ្ពស់។

- ផ្តល់តួនាទីឱ្យបានពេញលេញដល់យន្តការការងារកម្ពុជា-ចិន សម្រាប់កិច្ចសហប្រតិបត្តិវិនិយោគ និងសមត្ថភាពផលិត ជាមួយនឹងទស្សនៈវិស័យក្នុងការអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយជាគំរូនៃតំបន់សេដ្ឋកិច្ចពហុបំណង រួមគ្នាធ្វើការសិក្សាលើ «ច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា» នៅកម្ពុជា។ កសាងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ជាគម្រោងលេចធ្លោ និងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ដើម្បីទាក់ទាញបន្ថែមនូវសហគ្រាសចិន ដែលមានសមត្ថភាពក្នុងការបង្កើនការវិនិយោគនៅកម្ពុជា ខណៈលើកទឹកចិត្តកិច្ចសហប្រតិបត្តិការក្នុងចំណោមក្រុមហ៊ុននានានៃប្រទេសទាំងពីរលើវិស័យកសិ-ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន អគ្គិសនី ថាមពល និងកម្មន្តសាល។ ភាគីចិនគាំទ្រការអភិវឌ្ឍផ្លូវដែកនៅកម្ពុជា និងរួមគ្នាធ្វើការសិក្សាលើការរៀបចំផែនការបឋម និងការរចនា ក៏ដូចជាការសិក្សាសមិទ្ធលទ្ធភាពបច្ចេកទេស និងសេដ្ឋកិច្ច ខណៈធ្វើឱ្យប្រសើរឡើងនូវផ្លូវថ្នល់ ប្រព្រឹត្តកម្មទឹកកខ្វក់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំពារជាច្រើនទៀត ក៏ដូចជាកិច្ចសហប្រតិបត្តិការអគ្គិសនី និងបណ្តាញថាមពល។

- ពន្លឿនវឌ្ឍនភាពនៃច្រករបៀងមច្ឆា និងអង្ករ ដោយផ្តោតសំខាន់លើកសិផល ដូចជា ត្រី អង្ករ ផ្លែឈើត្រូពិច បន្លែ និងធាតុចូលកសិកម្មនានា (ជី ថ្នាំសម្លាប់សត្វល្អិត ចំណីសត្វ) ដើម្បីបង្កើនទំហំពាណិជ្ជកម្មកសិកម្មរវាងប្រទេសទាំងពីរ។ ដើម្បីសម្រេចគោលបំណងនៃច្រករបៀងមច្ឆា និងអង្ករ កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម គួរផ្តោតលើការអភិវឌ្ឍវារីវប្បកម្ម កសិកម្មកែច្នៃ កសិកម្មអេកូឡូស៊ី ម៉ាស៊ីនទំនើបៗ បច្ចេកវិទ្យាកសិកម្មថ្មី និងធនធានមនុស្ស។ តំបន់នានាដែលបង្ហាញពីកសិកម្មទំនើបនឹងត្រូវបានបង្កើតឡើងនៅកម្ពុជា ហើយកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរកសិកម្មឌីជីថលក៏នឹងត្រូវបានអនុវត្ត។

ធ្វើឱ្យស៊ីជម្រៅកិច្ចសហប្រតិបត្តិការលើការត្រួតពិនិត្យ និងចត្តាឡីស័ករវាងប្រទេសទាំងពីរ។ ស្វែងរកការផ្លាស់ប្តូរព័ត៌មានឆ្លងដែនផងដែរ តាមរយៈ «ច្រកចេញចូលតែមួយ» ខណៈធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការចត្តាឡីស័ករុក្ខជាតិ និងសត្វ សុវត្ថិភាពម្ហូបអាហារ និងពន្លឿនការចរចាលើពិធីសារចត្តាឡីស័កសម្រាប់ការនាំផលិតផលកសិកម្ម និងម្ហូបអាហារទៅចិន។

- ផ្តល់ឱ្យគណៈកម្មាធិការសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា-ចិន នូវតួនាទីដឹកនាំពេញលេញ ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការវិនិយោគ និងពាណិជ្ជកម្មដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមករវាងបណ្តាសហគ្រាសនៃប្រទេសទាំងពីរ។ អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ខណៈទាញយកឱ្យបានពេញលេញនូវសក្តានុពល នៃពាណិជ្ជកម្មទ្វេភាគី និងធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងនៃផលិតផលកម្ពុជានៅក្នុងប្រទេសចិន តាមរយៈយន្តការកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មអេឡិចត្រូនិកទ្វេភាគី ពិព័រណ៍នាំចូលអន្តរជាតិចិន ពិព័រណ៍នាំចេញ-នាំចូលចិន ពិព័រណ៍ផលិតផលអ្នកប្រើប្រាស់អន្តរជាតិចិន ពិព័រណ៍ពាណិជ្ជកម្មឌីជីថលសកល ពិព័រណ៍អាស៊ាន-ចិន។ល។ លើកកម្ពស់ការអនុវត្តប្រកបដោយគុណភាពខ្ពស់នូវកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ព្រមទាំងជំរុញការចរចាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០។ ភាគីកម្ពុជាគាំទ្រតំបន់រដ្ឋបាលពិសេសហុងកុងចូលរួមក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់។

- បង្កើនកិច្ចសហប្រតិបត្តិការលើវិស័យថាមពលវារីអគ្គិសនី ថាមពលដើរដោយពន្លឺព្រះអាទិត្យ និងប្រភពថាមពលស្អាតដទៃទៀត ដើម្បីស្វែងរកដំណោះស្រាយកិច្ចសហប្រតិបត្តិការថាមពលបៃតង ដែលមានស្ថិរភាព និងអាចទុកចិត្តបាន ជំរុញការបង្កើតគម្រោងតំបន់បង្ហាញការបញ្ចេញកាបូនទាបកម្ពុជា-ចិន នៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ស្តីពីការប្រែប្រួលអាកាសធាតុនៅខេត្តព្រះសីហនុ អនុវត្តកិច្ចសហប្រតិបត្តិក្នុងកិច្ចសន្ទនាគោលនយោបាយ ការស្រាវជ្រាវរួម និងការកសាងសមត្ថភាព ដោយផ្តោតសំខាន់លើការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងការបំពុលបរិស្ថាន និងសេដ្ឋកិច្ចចរន្ត អនុវត្តកិច្ចសហប្រតិបត្តិការលើវិស័យដែលជាប្រយោជន៍រួម ដូចជាការគ្រប់គ្រងធនធានទឹកឱ្យបានគ្រប់ជ្រុងជ្រោយ ការបង្ការគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ និងសុវត្ថិភាពទឹកបរិភោគនៅតាមជនបទ។

- រក្សាការចូលរួមយោធាកម្រិតខ្ពស់ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទងគ្នា និងការផ្លាស់ប្តូររវាងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃកងកម្លាំងប្រដាប់អាវុធទាំងពីរ ធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការជាក់ស្តែង ក្នុងការបណ្តុះបណ្តាល ការធ្វើសមយុទ្ធរួមគ្នា សេវាកម្មវេជ្ជសាស្ត្រ ភស្តុភារកម្ម និងការដោះមីន។ល។ ក៏ដូចជាការបង្កើនការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងវេទិកាពហុភាគី។

បន្តធ្វើឱ្យស៊ីជម្រៅកិច្ចសហប្រតិបត្តិការជាក់ស្តែងលើវិស័យនគរបាល និងការកសាងសមត្ថភាពទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៃប្រទេសទាំងពីរ ក្នុងការប្រយុទ្ធប្រឆាំងការលេងល្បែងស៊ីសងឆ្លងដែន ការបោកប្រាស់តាមប្រព័ន្ធទូរគមនាគមន៍ អនុវត្តកិច្ចសហប្រតិបត្តិការសន្តិសុខលើគម្រោងនៃខ្សែក្រវាត់ និងផ្លូវសំខាន់ៗ។

- ភាគីចិនបញ្ជាក់ការបន្តគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅកម្ពុជា តាមរយៈការអនុវត្តបន្ថែមទៀតនូវគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល និងគម្រោងនានាដូចជា ផ្លូវជនបទ ស្ពាន ការផ្គត់ផ្គង់ទឹក សាលារៀន និងមន្ទីរពេទ្យ។ ភាគីកម្ពុជាសូមថ្លែងអំណរអរគុណចំពោះការគាំទ្រយ៉ាងពេញទំហឹងរបស់ចិន។

- ភាគីកម្ពុជាបញ្ជាក់សាជាថ្មីនូវការស្វាគមន៍ដ៏កក់ក្តៅជូនចំពោះទេសចរចិន និងការប្តេជ្ញាចិត្តក្នុងការផ្តល់សន្តិសុខ និងសេវាកម្មប្រកបដោយគុណភាព។ ភាគីទាំងពីរឯកភាពគ្នាបង្កើនការផ្លាស់ប្តូររវាងស្ថាប័នទេសចរណ៍ និងវប្បធម៌/ក្រសួងទទួលបន្ទុកនៃប្រទេសទាំងពីរ ដើម្បីលើកកម្ពស់ការអនុវត្តកម្មវិធីប្រតិបត្តិ ស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌រវាងរដ្ឋាភិបាលទាំងពីរ ស្របពេលលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការរវាងវិស័យទេសចរណ៍ និងវប្បធម៌នៃប្រទេសទាំងពីរ តាមរយៈការអភិវឌ្ឍគម្រោងរួមនៃផលិតផលទេសចរណ៍ ធនធានមនុស្ស និងការគាំទ្រគ្នាទៅវិញទៅមកលើការផ្សព្វផ្សាយ និងទីផ្សារទេសចរណ៍ ក៏ដូចជាការគាំទ្រគ្រប់ជ្រុងជ្រោយនៅក្នុងកិច្ចប្រឹងប្រែងកសាងស្ថាប័ន។ បន្តអនុវត្តគម្រោងជំនួយរបស់ចិន ក្នុងការជួសជុលព្រះបរមរាជវាំងនៅអង្គរ និងជំរុញកិច្ចសហប្រតិបត្តិការក្នុងការការពារ និងការជួសជុលប្រាសាទព្រះវិហារ និងបេតិកភណ្ឌវប្បធម៌ដទៃទៀត។ គាំទ្រសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសនៃប្រទេសទាំងពីរ ដើម្បីបង្កើនជើងហោះហើរ

កម្ពុជា-ចិន ស្របតាមតម្រូវការទីផ្សារ ដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មទ្វេភាគី និងការផ្លាស់ប្ដូរមន្ត្រី។

បន្តគាំទ្រយុវជនកម្ពុជាទៅសិក្សានៅប្រទេសចិន។ លើកកម្ពស់ផ្ទះយុវជនសម្រាប់មិត្តភាពកម្ពុជា-ចិន ឱ្យក្លាយជាវេទិកាសម្រាប់ពង្រឹងការផ្លាស់ប្ដូរ និងបណ្ដុះបណ្ដាលយុវជនរវាងប្រទេសទាំងពីរ។ ជំរុញការបង្កើតវិទ្យាស្ថានខុងជឺ និងការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់នៃការអប់រំភាសាចិននៅកម្ពុជា។ ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើការអប់រំវិជ្ជាជីវៈ ក្នុងក្របខណ្ឌនៃសម្ព័ន្ធអប់រំវិជ្ជាជីវៈកម្ពុជា-ចិន ខណៈលើកកម្ពស់ការទទួលស្គាល់គ្នាទៅវិញទៅមកនៃស្តង់ដារចុះឈ្មោះជំនាញវិជ្ជាជីវៈ។ ភាគីចិននឹងបន្តផ្ដល់អាហារូបករណ៍របស់រដ្ឋាភិបាលចិនដល់និស្សិតកម្ពុជា។

បង្កើនការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល រួមទាំងឱសថបុរាណចិន និងវិទ្យាសាស្ត្រវេជ្ជសាស្ត្របុរាណចិន ជំរុញការបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការឱសថបុរាណកម្ពុជា-ចិន។ ភាគីចិននឹងបន្តបញ្ជូនក្រុមគ្រូពេទ្យឱសថបុរាណចិនមកកម្ពុជា។

ភាគីទាំងពីរគាំទ្រការផ្លាស់ប្ដូរប្រជាជន-ប្រជាជនគ្រប់ទម្រង់ និងជំរុញគម្រោងកិច្ចសហប្រតិបត្តិការ ដើម្បីធ្វើឱ្យស៊ីជម្រៅនៃការផ្លាស់ប្ដូរអរិយធម៌ និងការលើកកម្ពស់ជីវភាពរវាងអង្គការក្រៅរដ្ឋាភិបាលនៃប្រទេសទាំងពីរ ក្នុងគោលបំណងជំរុញការស្វែងយល់ពីគ្នាទៅវិញទៅមករវាងប្រជាជនទាំងពីរ។

៦. ភាគីទាំងពីរត្រៀមខ្លួនរួចជាស្រេច ដើម្បីការពារប្រព័ន្ធអន្តរជាតិដែលមានអង្គការសហប្រជាជាតិជាស្នូល សណ្ដាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់អន្តរជាតិ និងបទដ្ឋានជាមូលដ្ឋានសម្រាប់គ្រប់គ្រងទំនាក់ទំនងអន្តរជាតិ ដូចមានចែងក្នុងគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ ភាគីទាំងពីរប្រឆាំងរាល់គ្រប់ទម្រង់នៃអនុត្តរភាព នយោបាយអំណាច ឯកតោភាគីនិយមក្នុងរូបភាពណាមួយ និងប្លុកផ្ដាច់មុខដែលផ្ដោតលើប្រទេសជាក់លាក់មួយ។ ប្រទេសទាំងពីរប្ដេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការលើការកសាងទំនាក់ទំនងអន្តរជាតិប្រភេទថ្មី និងកសាងសហគមន៍វាសនារួមសម្រាប់មនុស្សជាតិដ៏ប្រសើរមួយ។

ភាគីទាំងពីរត្រៀមខ្លួនរួចជាស្រេច ដើម្បីការពារបទដ្ឋានជាមូលដ្ឋាន និងគុណតម្លៃស្នូលនៃអង្គការពាណិជ្ជកម្មពិភពលោក និងគាំទ្រដល់កំណែទម្រង់នានារបស់អង្គការនេះ ជាពិសេសការស្ដារនិងដំណើរការធម្មតានៃយន្តការដោះស្រាយជម្លោះកម្រិតពីរដែលមានលក្ខណៈចាប់បង្ខំ។ ប្រទេសទាំងពីរ ដែលសុទ្ធតែជាប្រទេសកំពុងអភិវឌ្ឍ មានឆន្ទៈក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីរួមគ្នាការពារសិទ្ធស្របច្បាប់នៃសមាជិកជាប្រទេសកំពុងអភិវឌ្ឍ និងលើកកម្ពស់តួនាទីរបស់អង្គការនេះឱ្យកាន់តែប្រសើរឡើង។

ភាគីទាំងពីរឯកភាពគ្នាប្រកាន់ខ្ជាប់នូវពហុភាគីនិយមពិតប្រាកដ។ ភាគីកម្ពុជាកោតសរសើរចំពោះតួនាទីមានលក្ខណៈស្ថាបនារបស់ចិន ក្នុងការលើកកម្ពស់សន្តិភាព និងការអភិវឌ្ឍជាសាកល ហើយត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមក្នុងកិច្ចសហប្រតិបត្តិការនៃគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍សកល

ដើម្បីឆ្ពោះទៅរកការអនុវត្តឱ្យបានឆាប់នូវរបៀបវារៈរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០៣០ សម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាគាំទ្រគំនិតផ្តួចផ្តើមសន្តិសុខសកល និងគំនិតផ្តួចផ្តើមអរិយធម៌សកល ហើយត្រៀមខ្លួនរួចជាស្រេចដើម្បីធ្វើការជាមួយចិន ស្តីពីអភិបាលកិច្ចសន្តិសុខសកល ឆ្ពោះទៅសម្រេចបានសន្តិសុខរួមប្រកបដោយចីរភាព សហប្រតិបត្តិការ និងគ្រប់ជ្រុងជ្រោយ និងប្រកាន់ខ្ជាប់នូវគុណតម្លៃរួមរបស់មនុស្សជាតិ ដូចជាសន្តិភាព ការអភិវឌ្ឍ សមធម៌ យុត្តិធម៌ ប្រជាធិបតេយ្យ និងសេរីភាព។

ភាគីទាំងពីរបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះតំបន់ភាវូបនីយកម្មដែលបើកចំហ ដើម្បីឈានទៅការកសាងផ្ទះសន្តិភាព សុវត្ថិភាព សន្តិសុខ វិបុលភាព ភាពស្រស់បំព្រង និងមិត្តភាព នៅក្នុងតំបន់ និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ចិន ដើម្បីកសាងសហគមន៍វាសនារួមអាស៊ាន-ចិន ឱ្យកាន់តែជិតស្និទ្ធថែមទៀត។ ភាគីទាំងពីរឯកភាពគ្នាបង្កើនកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដើម្បីជំរុញការកសាងសហគមន៍វាសនារួមសម្រាប់ប្រទេសមេគង្គ-ឡានឆាង ឱ្យកាន់តែជិតស្និទ្ធថែមទៀត។

៧. ភាគីទាំងពីរជឿជាក់ថា ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នានៃប្រទេសសមាជិកអាស៊ាន និងចិន ស្ថានភាពនៅសមុទ្រចិនខាងត្បូងរក្សាបាននូវស្ថិរភាពជារួម។ ប្រទេសទាំងពីរបានអំពាវនាវដល់ភាគីពាក់ព័ន្ធអនុវត្តឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការលម្អសមុទ្រ និងសម្រេចឱ្យបានឆាប់នូវក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង ប្រកបដោយសារសំខាន់ និងប្រសិទ្ធភាព ឈរលើមូលដ្ឋាននៃការឯកភាពជាឯកច្ឆន្ទទៅវិញទៅមក ដើម្បីកសាងសមុទ្រចិនខាងត្បូង ទៅជាសមុទ្រសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការ។ រាល់ការប៉ុនប៉ងណាមួយក្នុងការប្រើប្រាស់បញ្ហាសមុទ្រចិនខាងត្បូង ដើម្បីបំផ្លាញសន្តិភាព ស្ថិរភាព និងភាពជឿជាក់ក្នុងតំបន់ពុំមានលទ្ធផលល្អឡើយ ហើយគួរតែត្រូវចៀសវាង។

៨. ភាគីទាំងពីរបានសម្តែងនូវការពេញចិត្ត ចំពោះលទ្ធផលនៃដំណើរទស្សនកិច្ចនេះ។ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជូនថ្នាក់ដឹកនាំ និងប្រជាជនចិន ចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និងប្រកបដោយមិត្តភាព ព្រមទាំងបានអញ្ជើញថ្នាក់ដឹកនាំចិន ទៅបំពេញទស្សនកិច្ចនៅកម្ពុជាតាមពេលវេលាសមស្រប។

ក្នុងឱកាសទស្សនកិច្ចនេះ ភាគីទាំងពីរបានចុះហត្ថលេខាលើផែនការសកម្មភាពនៃការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន (ឆ្នាំ២០២៤-២០២៨) និងឯកសារកិច្ចសហប្រតិបត្តិការមួយចំនួនទៀតស្តីពីៈ «ច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា» «ច្រករបៀងមច្ឆា និងអង្ករ» ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចឌីជីថល ការអភិវឌ្ឍបៃតង ការត្រួតពិនិត្យ និងចត្តាឡីស័ក ព្រៃឈើ និងសត្វព្រៃ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

ទីក្រុងប៉េកាំង ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣